ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......៦៧៦៦......អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារកាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ-អាករ ប្រចាំខែមីនា ឆ្នាំ២០១៧

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ដោយកាលបរិច្ឆេទផុតកំណត់នៃការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ-អាករគ្រប់ប្រភេទប្រចាំខែមីនា ត្រូវជិតទៅនឹងថ្ងៃប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរ ប្រពៃណីជាតិ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ចាប់ពីថ្ងៃទី ១៤-១៦ ខែមេសា ឆ្នាំ២០១៧។ ដូចនេះ ដើម្បីឱ្យអ្នកជាប់ពន្ធមានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំលិខិតប្រកាសបង់ពន្ធប្រចាំខែ អគ្គនាយកដ្ឋានពន្ធដារសម្រេចពន្យារកាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ ប្រចាំខែមីនា ឆ្នាំ២០១៧ រហូតដល់ **ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧**។ សម្រាប់ខែបន្តបន្ទាប់ត្រូវអនុវត្តជាធម្មតា ដូចមានចែងក្នុងសេចក្តីជូនដំណឹងលេខ ៩៣១ អពដ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថា ការពន្យារកាលបរិច្ឆេទដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ-អាករ នេះនឹងជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

ចម្លងជូន៖
- ក្រុមការងារ ICT
- ឯកសារ-កាលប្បវត្តិ

អាគារតេជោមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh